**សេចក្តីប្រកាសព័ត៌មាន**

**នគរបាលជាតិកម្ពុជា-កូរ៉េ ព្រមព្រៀងគ្នាពង្រឹងកិច្ចសហប្រតិបត្តិការ**

**ប្រឆាំងនឹងបទល្មើសឆ្លងដែនបន្ថែមទៀត**

- **ការពង្រីកវិសាលភាពប្រតិបត្តិការរបស់ "ក្រុមការងាររួមកម្ពុជា-កូរ៉េ សម្រាប់ពលរដ្ឋកូរ៉េ" ដោយរួមបញ្ចូលបទល្មើសគ្រឿងញៀន និងល្បែងស៊ីសងខុសច្បាប់**
- **ការចែករំលែកបទពិសោធន៍រវាងនគរបាលកូរ៉េ និងនគរបាលជាតិកម្ពុជា ដើម្បីពង្រឹងការការពារពលរដ្ឋកូរ៉េនៅព្រះរាជាណាចក្រកម្ពុជានិងការឆ្លើយតបនឹងបទល្មើសឆ្លងដែន**

ថ្ងៃពុធ ទី២៩ ខែមេសា ឆ្នាំ ២០២៦

ទីភ្នាក់ងារនគរបាលជាតិកូរ៉េ (KNPA) ដឹកនាំដោយលោក YOO Jae Seong អគ្គស្នងការស្តីទីនគរបាលជាតិ បានបើកកិច្ចប្រជុំកំពូលនគរបាលជាតិកូរ៉េ-កម្ពុជា ជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា (CNP) ដឹកនាំដោយនាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការនគរបាលជាតិ នៅថ្ងៃទី២៩ ខែមេសា ដើម្បីពិភាក្សាអំពីវិធីសាស្ត្រយុទ្ធសាស្ត្រ ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកងកម្លាំងនគរបាលនៃប្រទេសទាំងពីរឱ្យកាន់តែរឹងមាំបន្ថែមទៀត។

ថ្នាក់ដឹកនាំនៃកងកម្លាំងនគរបាលជាតិនៃប្រទេសទាំងពីរ បានបង្ហាញនូវទស្សនៈរួមថា បណ្តាញឧក្រិដ្ឋកម្មឆ្លងដែន រួមទាំងក្រុមធ្វើប្រតិបត្តិការមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា គឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ពិភពលោក ដោយបានបញ្ជាក់នូវការប្តេជ្ញាចិត្តជាថ្មីថា កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ និងសាមគ្គីភាពរបស់កងកម្លាំងនគរបាល គឺមានសារៈសំខាន់ខ្លាំងក្នុងការធានាសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋនៃប្រទេសទាំង២ និងការកសាងសន្តិសុខសាធារណៈក្នុងតំបន់។

ទន្ទឹមនឹងការវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដែលសម្រេចបាន ដោយក្រុមការងាររួមកម្ពុជា-កូរ៉េ សម្រាប់ពលរដ្ឋកូរ៉េ (CKJTFK) អគ្គស្នងការនគរបាលជាតិទាំងពីរបានព្រមព្រៀងគ្នាពង្រីកវិសាលភាពប្រតិបត្តិការរបស់ក្រុមការងារ CKJTFK។ បន្ទាប់ពីថ្នាក់ដឹកនាំនៃកងកម្លាំងនគរបាលប្រទេសទាំងពីរបានព្រមព្រៀងគ្នាក្នុងការបង្កើតក្រុមការងាររួមនេះ នៅក្នុងកិច្ចប្រជុំកំពូល កាលពីខែតុលា ឆ្នាំ២០២៥ មន្ត្រីនគរបាលកូរ៉េបាននិងកំពុងធ្វើការរួមគ្នាជាមួយមន្ត្រីនគរបាលកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងបទល្មើសពាក់ព័ន្ធផ្សេងទៀតប្រឆាំងនឹងពលរដ្ឋកូរ៉េ ចាប់តាំងពីខែធ្នូ ឆ្នាំ២០២៥កន្លងមក។

**លទ្ធផលការងារលេចធ្លោរបស់ក្រុមការងារ CKJTFK បាននាំឱ្យមានការពង្រីកកិច្ចសហប្រតិបត្តិការរបស់ខ្លួន**

**ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការការពារពលរដ្ឋកូរ៉េនៅព្រះរាជាណាចក្រកម្ពុជា**

ក្នុងអំឡុងប្រតិបត្តិការយ៉ាងសកម្មរយៈពេល ៤ ខែ (ចាប់ពីខែធ្នូឆ្នាំ២០២៥ ដល់ខែមីនាឆ្នាំ២០២៦) ក្រុមការងារ CKJTFK ទទួលបានជោគជ័យក្នុងការចាប់ខ្លួនឧក្រិដ្ឋជនសំខាន់ៗសរុបចំនួន ១៦៦នាក់ រួមទាំងជនជាតិកូរ៉េ

ដែលរត់គេចខ្លួនចូលមកសម្ងំនៅប្រទេសកម្ពុជា និងបានជួយសង្គ្រោះពលរដ្ឋកូរ៉េចំនួន ៥ រូប ពីការឃុំឃាំង ដែលបង្ហាញពីប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរ ក្នុងការការពារពលរដ្ឋកូរ៉េនៅព្រះរាជាណាចក្រកម្ពុជា។

ផ្អែកលើលទ្ធផលការងារលេចធ្លោទាំងនេះ ថ្នាក់ដឹកនាំនៃកងកម្លាំងនគរបាលនៃប្រទេសទាំងពីរ បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្ត ក្នុងការលុបបំបាត់បទល្មើសឆ្លងដែនតាមរយៈការឈានដល់កិច្ចព្រមព្រៀង ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការរបស់ក្រុមការងារ CKJTFK ដែលបច្ចុប្បន្នមានកម្រិតត្រឹមតែបទល្មើសពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដោយដាក់រួមបញ្ចូលទាំងបទល្មើសគ្រឿងញៀន និងល្បែងស៊ីសងខុសច្បាប់។ ការពង្រីកកិច្ចសហប្រតិបត្តិការនេះត្រូវបានចាត់ទុកថាជាវិធានការបុរេសកម្ម នឹងជួយជំរុញដល់ការចែករំលែកព័ត៌មានតាមពេលវេលាជាក់ស្តែង និងប្រតិបត្តិការស៊ើបអង្កេតរួមគ្នា ស្របតាមច្បាប់និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ ដើម្បីឆ្លើយតបទៅនឹងបណ្តាញឧក្រិដ្ឋជន ដែលកំពុងពង្រីកវិសាលភាពបង្កើតមជ្ឈមណ្ឌលយុទ្ធសាស្ត្ររបស់ពួកគេ នៅអាស៊ី អាគ្នេយ៍។

**តាមរយៈគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) នៃការងារនគរបាលកូរ៉េ "K-policing" ទីភ្នាក់ងារនគរបាលជាតិកូរ៉េ (KNPA) និង នគរបាលជាតិកម្ពុជា (CNP) កំពុងឈានមុខគេ ក្នុងការឆ្លើយតបនឹងបទល្មើសឆ្លងដែនក្នុងតំបន់**

លើសពីនេះ KNPA ប្តេជ្ញាពង្រឹងសមត្ថភាពនគរបាលកម្ពុជា តាមរយៈការចែករំលែកប្រព័ន្ធទំនើបកម្មការងារនគរបាល និងបច្ចេកទេសស៊ើបអង្កេតតាមរយៈគម្រោង ODA របស់ខ្លួន។ ជាពិសេស តាមរយៈកិច្ចសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) KNPA នឹងបន្តគម្រោង ODA ស្តីពីការពង្រឹងសមត្ថភាពការងារស៊ើបអង្កេតកន្លែងកើតហេតុ (CSI) និងវិទ្យាសាស្ត្រកោសល្យវិច័យ ដល់ក្រសួងមហាផ្ទៃ ដែលមានតម្លៃ ១៨ ពាន់លានវ៉ុន ដែលមួយផ្នែកនៃជំនួយនេះ ត្រូវបានផ្តល់ជូនដល់ CNP ដើម្បីជួយពង្រឹងសមត្ថភាព ក្នុងការឆ្លើយតបទៅនឹងបទល្មើសឆ្លងដែនដែលកាន់តែមានលក្ខណៈស្មុគស្មាញ។

គម្រោងសហប្រតិបត្តិការទាំងនេះត្រូវបានរំពឹងថា នឹងជួយពង្រឹងសុវត្ថិភាពដល់ពលរដ្ឋកម្ពុជា កូរ៉េ ព្រមទាំងពង្រឹងភាពជាដៃគូរវាងនគរបាលនៃប្រទេសទាំង២ ដើម្បីឆ្លើយតបទៅនឹងបទល្មើសឆ្លងដែនគ្រប់ប្រភេទ។

លោក PARK Jun Sung អគ្គនាយកស្តីទីទទួលបន្ទុកកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ KNPA បានថ្លែងថា៖ "កិច្ចប្រជុំកំពូលនគរបាលនេះ គឺជាសក្ខីភាពនៃចំណុចរបត់ដ៏សំខាន់មួយ ដោយបញ្ជាក់ជាថ្មីនូវទំនុកចិត្តយ៉ាងរឹងមាំរវាងភ្នាក់ងារនគរបាលទាំងពីរ និងបង្កើតជាកម្លាំងជួរមុខការពាររួមគ្នាប្រឆាំងនឹងបទល្មើសឆ្លងដែនដែលកាន់តែមានលក្ខណៈស្មុគស្មាញ" និង "តាមរយៈការគ្រប់គ្រងជាយុទ្ធសាស្ត្រលើក្រុមការងារ CKJTFK និងការលើកកម្ពស់គុណភាពនៃគម្រោងការងារនគរបាល Policing ODA យើងនឹងធានាបាននូវការការពារយ៉ាងហ្មត់ចត់ដល់ពលរដ្ឋរបស់យើង ឱ្យរួចផុតពីបទល្មើសនានា និងដើរតួនាទីឈានមុខគេក្នុងការការពារសុវត្ថិភាពនៅទូទាំងអាស៊ី"៕